ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ...០៧៤.........អ.ស.ហ.ប្រ.ក.

# ប្រកាស
## ស្តីពី
## ការបញ្ចូលមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ និងជាអង្គភាពបរិវត្តកម្មឌីជីថលនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅក្នុងយន្តការគណៈកម្មការអន្តរក្រសួងគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russel Keo, Phnom Penh
Website: fsa.gov.kh, Telegram: t.me/fsacambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩០ ៧០០
Phone: (+855) 23 990 700
info@fsa.gov.kh

- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ស្តីពីការបំពាក់មុខងារបន្ថែមឱ្យមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារជាអង្គភាពបរិវត្តកម្មឌីជីថលនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ១០៧ សហវ.ប្រក.ន.អ.ប ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា
- បានឃើញប្រកាសលេខ ០០៤ អ.ស.ហ.ប្រក. ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០០៨ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

# សម្រេច

**ប្រការ១.-**

ត្រូវបានបញ្ចូល "មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនិងជាអង្គភាពបរិវត្តកម្មឌីជីថលនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)" ទៅក្នុងយន្តការគណៈកម្មការអន្តរក្រសួងគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា (គ.ទ.អ.) ដើម្បីជានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា សំដៅជំរុញ គាំទ្រ និងពន្លឿនបរិវត្តកម្មឌីជីថលផ្អែកលើទិន្នន័យក្នុងវិស័យហិរញ្ញវត្ថុ ស្របតាមប្រព័ន្ធអេកូឡូស៊ីទិន្នន័យនៃ អ.ស.ហ.។

**ប្រការ២.-**

មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនិងជាអង្គភាពបរិវត្តកម្មឌីជីថលនៃ អ.ស.ហ. ត្រូវបំពេញមុខងារជាសេនាធិការបច្ចេកទេសជូន គ.ទ.អ. និងលេខាធិការដ្ឋាន គ.ទ.អ. លើការជំរុញ ការគាំទ្រ និងការពន្លឿនការងារពាក់ព័ន្ធនឹងការគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សិក្សាអំពីថ្នាលគ្រប់គ្រងទិន្នន័យអចលនទ្រព្យ ព្រមទាំងក្របខណ្ឌនិង/ឬបទប្បញ្ញត្តិគាំទ្រពាក់ព័ន្ធ
- រៀបចំនិងធ្វើវិសិដ្ឋកម្មថ្នាលគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា
- គាំទ្រនិងជំរុញការប្រើប្រាស់ថ្នាលគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា
- រៀបចំក្របខណ្ឌនិង/ឬបទប្បញ្ញត្តិគាំទ្រដល់ប្រព័ន្ធអេកូឡូស៊ីថ្នាលគ្រប់គ្រងទិន្នន័យអចលនទ្រព្យនៅកម្ពុជា
- សម្របសម្រួលនិងធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹង គ.ទ.អ. និងលេខាធិការដ្ឋាន គ.ទ.អ. ព្រមទាំងក្រសួង-ស្ថាប័ននិងអង្គភាពពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍ ស្របតាមអភិក្រមរដ្ឋាភិបាលទាំងមូលនិងជវភាពនៃប្រព័ន្ធតួអង្គតែមួយ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ អ.ស.ហ.។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និងប្រធានអង្គភាពក្រោមឱវាទ អ.ស.ហ. ព្រមទាំងប្រធាន គ.ទ.អ. ប្រធានលេខាធិការដ្ឋាន គ.ទ.អ. និងប្រធានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនិងជាអង្គភាពបរិវត្តកម្មឌីជីថលនៃ អ.ស.ហ. ក៏ដូចជាប្រធានអង្គភាពនៃក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១១ កើត ខែ អស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ តុលា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអភិបាលសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.
- និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ
- គ.ទ.អ. និងលេខាធិការដ្ឋាន គ.ទ.អ.
- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនិងជាអង្គភាពបរិវត្តកម្មឌីជីថលនៃ អ.ស.ហ.
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ